ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កណ្តែក

រយ:ពេល ០៣ឆ្នាំ

ខែមីនា ឆ្នាំ២០២០ ~ ខែមីនា ឆ្នាំ២០២៣

ឈ្មោះសហគមន៍នេសាទ : កណ្តែក

ភូមិ : ប្រែស គោកធ្លក អូរ ឃុនមោក ត្រពាំងទឹម និងល្អក់

ឃុំ : កណ្តែក

ស្រុក : ប្រាសាទបាគង

ខេត្ត : សៀមរាប

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កណ្តោក

រយៈពេល ០៣ឆ្នាំ

ខែមីនា ឆ្នាំ២០២០ ~ ខែមីនា ឆ្នាំ២០២៣

| | | |
|---|---|---|
| កន្លែងនេសាទសហគមន៍ | ៖ | កណ្តោក |
| ភូមិ | ៖ | ច្រេស គោកធ្លក អូរ ឃុនមោក ត្រពាំងទឹម និងល្អក់ |
| ឃុំ | ៖ | កណ្តោក |
| ស្រុក | ៖ | ប្រាសាទបាគង |
| ខេត្ត | ៖ | សៀមរាប |

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

# មាតិកា


១.ស្ថានភាពទូទៅ ..... ១
២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..... ២
ក.ប្រជាពលរដ្ឋ ..... ២
ខ. មុខរបរ ..... ២
៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ..... ៣
ក. ទីតាំង ..... ៣
ខ. ដែននេសាទ ..... ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ..... ៤
ឃ. ធនធានជលផល ..... ៤
ឃ-១.តារាងប្រភេទផលនេសាទ ..... ៦
ឃ-២.តារាងប្រភេទវារីសត្វនិងបក្សីទឹក ..... ៦
ឃ-៣.តារាងប្រភេទព្រៃលិចទឹក និងរុក្ខជាតិទឹក ..... ៧
៤.ការធ្វើនេសាទ ..... ៦
ក.អ្នកនេសាទ ..... ៧
ខ.ឧបករណ៍នេសាទ ..... ៧
គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ ..... ៩
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៩
ក.ទស្សនៈវិស័យ ..... ៩
ខ.គោលបំណង ..... ៩
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៩
គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ..... ៩
គ.២. ផែនការកែលម្អដែននេសាទ ..... ១០
គ.៣. ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ..... ១១
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ..... ១១
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ..... ១២
គ.៦.ផែនការរកប្រាក់ចំណូលសហគមន៍ ..... ១២
គ.៧. ផែនការអភិវឌ្ឍន៍ផ្សេងៗទៀត(ផែនការសមាហរណកម្មជាមួយឃុំ) ..... ១៣

គ.៧-១.ផែនការគ្រប់គ្រងសហគមន៍២០២០-២០២៣ ............................................. ១៣
គ.៧-២.ផែនការសហគ្រាសខ្នាតតូច ............................................. ១៣
គ.៧-៣. ផែនការអភិវឌ្ឍន៍ភូមិ ............................................. ១៣
ឃ.ផែនការយុទ្ធសាស្ត្រ ............................................. ១៤

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កណ្ដោក រយៈពេល០៣ឆ្នាំ ឆ្នាំ២០២០-២០២៣ .. ១៥
-តារាងកម្មវិធីផែនការអភិវឌ្ឍន៍ផ្សេងៗសម្រាប់ផែនការសមាហរណកម្មជាមួយភូមិ-ឃុំ២០២០-២០២៣ ..... ១៧
-តារាងកម្មវិធីការងារសហគមន៍នេសាទកណ្ដោក រយៈពេល០៣ឆ្នាំ ឆ្នាំ២០២០-២០២៣ ............................................. ២០

ឧបសម្ពន្ធ១៖ ផែនទីប្រើប្រាស់ និងផែនការគ្រប់គ្រងធនធានធម្មជាតិសហគមន៍នេសាទកណ្ដោក

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍កណ្ដែក

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទកណ្តែកបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ ដោយមានការសហការរៀបចំពីអាជ្ញាធរដែនដី ជំនាញជលផលព្រមទាំងមានការគាំទ្របច្ចេកទេសពីគម្រោង ការចូលរួមគ្រប់គ្រងធនធានធម្មជាតិតំបន់បឹងទន្លេសាបប្រចាំខេត្តសៀមរាប ដោយមានការជួយឧបត្ថម្ភពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ ហើយគម្រោងបានដំណើរការធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧។

សហគមន៍នេសាទកណ្តែកមានទីតាំងស្ថិតនៅក្នុងភូមិច្រេស ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ មានប្រជាពលរដ្ឋជាសមាជិកសហគមន៍ចំនួន១៥៥០គ្រួសារ ក្នុងនោះមានស្រីចំនួន៧៤៣ នាក់និងមានគណៈកម្មការចំនួន១១ នាក់ ស្រី០១ នាក់។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន១០៨៣ គ្រួសារ។

ដោយមានការជួយគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ សហគមន៍នេសាទបានដំណើរ ការសកម្មភាពសំខាន់ៗរបស់ខ្លួនមានដូចជា:

រៀបចំចងក្រងរចនាសម្ព័ន្ធសហគមន៍នេសាទ តាមរយៈការអប់រំបណ្តុះបណ្តាលដល់គណៈកម្មការសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើនសមត្ថភាពយល់ដឹងអំពីការគ្រប់គ្រងសហគមន៍នេសាទ។ ជាអាទិ៍មានការផ្តួចផ្តើមគំនិតរៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ការរៀបចំមហាសន្និបាត ការកំណត់ព្រំប្រទល់សហគមន៍នេសាទ ការចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ការចុះបញ្ជី ការទទួលស្គាល់សហគមន៍នេសាទ និងការរៀបចំផែនការគ្រប់ គ្រង។

ផ្សព្វផ្សាយលក្ខន្តិកៈតាមបណ្តាភូមិក្នុងសហគមន៍និងឃុំពាក់ព័ន្ធដែលជាប្រជានេសាទមកពីក្រៅសហគមន៍ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងការងារប្រជុំបណ្តាញសហគមន៍ នៅខណ្ឌរដ្ឋបាលជលផលសៀមរាប។

ការផ្តល់ប្រតិភូកម្មអំណាចដល់សហគមន៍ក្នុងការគ្រប់គ្រងធនធានក្នុងសហគមន៍បន្ទាប់ពីការរៀបចំរចនាសម្ព័ន្ធសហគមន៍រួចមក គណៈកម្មការបានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិក្នុងដែននេសាទសហគមន៍។ មិនតែប៉ុណ្ណោះបានបង្កើតដែនអភិរក្សនាទីព្រៃលិចទឹក ក្នុងកន្លែងនេសាទសហគមន៍។ ពង្រឹងកិច្ចសហ-ការទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងដែននេសាទសហគមន៍(ការកាប់ព្រៃលិចទឹក និងការនេសាទខុសច្បាប់ ) ដោយសហការជាមួយសង្កាត់នេសាទប្រចាំតំបន់កំពង់ភ្លុក។ ចូលរួមដោះស្រាយទំនាស់ក្នុងសហគមន៍នេសាទ (បញ្ហាព្រំប្រ-ទល់សហគមន៍ រវាងសហគមន៍នេសាទកណ្តែក និងសហគមន៍នេសាទកំពង់ភ្លុក)។ ចូលរួមសហការការងារជាមួយ អង្គការអន្តរជាតិនានាដូចជាCFDS. ADB. FACT. TSSLP.។ល។ ដើម្បីដំណើរការអភិវឌ្ឍន៍ក្នុងសហគមន៍។ ការ គាំទ្រ

មុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពមួយដ៏ចំបងដែលជួយ ពង្រឹងមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេសគឺជួយកាត់បន្ថយលើសម្ពាធ នៃការធ្វើអាជីវកម្មនេសាទហួសកម្រិត។

ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារអោយមានការរីកចំរើនឡើង។

## ២- អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ

ឃុំកណ្ដោកមាន ១០ ភូមិ គឺភូមិគោកធ្លក ត្រពាំងទឹម ឃុនមោក ប្រេស អូរ ស្ពានក្អែក ត្រាង ជ្រៃ គោកត្នោត និងភូមិល្អក់ ដោយឡែកប្រជាពលរដ្ឋបានចូលជាសមាជិកសហគមន៍នេសាទមានចំនួន០៦ ភូមិ តែប៉ុណ្ណោះ គឺភូមិ គោកធ្លក ត្រពាំងទឹម ឃុនមោយ ប្រេស ភូមិអូរ និងភូមិល្អក់។ រីឯ០៤ ភូមិទៀត គឺភូមិស្ពានក្អែក ត្រាង ជ្រៃ និង គោកត្នោត មានទីតាំងនៅលើថ្នល់ជាតិ។

ប្រជាពលរដ្ឋទាំង០៦ភូមិ សរុបចំនួន២៦៤០ គ្រួសារ ដែលមានប្រជាពលរដ្ឋសរុបចំនួន៩៤៩២ នាក់ ក្នុងនោះមាន ស្ត្រីចំនួន៤៨២៣ នាក់ ។

ផ្អែកតាមស្ថិតិប្រជាពលរដ្ឋក្នុងឃុំបានបង្ហាញនូវកំណើនប្រជាជននៅក្នុងឃុំទាំងមូលមានការកើនឡើងជាលំដាប់ ស្ថានភាពប្រជាពលរដ្ឋក្នុងសហគមន៍នេសាទមានៈ ប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមានចំនួន១៥៥០នាក់ ក្នុងនោះមាន ស្ត្រីចំនួន៧៤៣ នាក់។

ជាទូទៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទ ទាំងមូលជាជនជាតិខ្មែរ ។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទ ចំនួន ១១៨ នាក់
- ជនពិការក្នុងសហគមន៍នេសាទ ចំនួន ១៤៦ នាក់ ក្នុងនោះមានស្ត្រី ៥២ នាក់
- ចាស់ជរាក្នុងសហគមន៍នេសាទ ចំនួន ៣៤ នាក់ ក្នុងនោះមានស្រី ១៥ នាក់
- កុមារកំព្រាក្នុងសហគមន៍នេសាទចំនួន ៣៣ នាក់ ក្នុងនោះមានស្រី ២០ នាក់
- អ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទ ចំនួន ០៣ នាក់ ក្នុងនោះមានស្ត្រី ០៤ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់មានអ្នកមិនចេះអក្សរចំនួន ២៨១ នាក់ ក្នុងនោះមានស្ត្រី ៨៩ នាក់
- កំរិតថ្នាក់បឋមសិក្សាចំនួន ១១២៦ នាក់ ក្នុងនោះមានស្រី ៥៩៤ នាក់
- កំរិតមធ្យមសិក្សាចំនួន ៩៤១ នាក់ ក្នុងនោះមានស្រី ៤៥៧ នាក់
- កំរិតឧត្តមសិក្សាចំនួន ១៨២ នាក់ ក្នុងនោះមានស្រី ១០៩ នាក់ ។

### ខ-មុខរបរ

ការប្រកបមុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុង**ឃុំកណ្ដោក** គឺចំនួន៧០%ធ្វើស្រែប្រាំងនិងធ្វើនេសាទក្រៅពីនេះ មានការលក់ដូរ ធ្វើកម្មករ ចិញ្ចឹមត្រី ជាងធ្វើផ្ទះ ដាំបន្លែ។ល។មុខរបរសំខាន់ៗ របស់ប្រជាពលរដ្ឋក្នុង សហគមន៍មាន:

-ធ្វើនេសាទចំនួន ៤២ គ្រួសារ

-ធ្វើស្រែចំនួន ១៤០១ គ្រួសារ ( របើផ្ទៃដីចំនួន ៧២៧ ហិកតា )

-ធ្វើវារីវប្បកម្មចំនួន ០៣ គ្រួសារ

-ជាងផ្ទះ ចំនួន ៤៥ គ្រួសារ

-ធ្វើចំការចំនួន ១១៣ គ្រួសារ

-លក់ដូរ ចំនួន ១១៣ គ្រួសារ

-កម្មករចំនួន ៦២០ គ្រួសារ

-ប្រាក់ចំណូលជាមធ្យមក្នុង ០១គ្រួសារប្រចាំឆ្នាំមានចំនួន ២ ៤០០ ០០០ រៀល ។

## ៣- កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក-ទីតាំង

កន្លែងនេសាទសហគមន៍កណ្តែក ជាកន្លែង ដែននេសាទទឹកសាប។

កន្លែងនេសាទសហគមន៍កណ្តែក មានទំហំ **២៧៤៧ ហិកតា** និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

សហគមន៍នេសាទមានព្រំប្រទល់:

-ខាងជើងទល់និងទំនប់ ៧៨ (X 382000, X 1469200)

-ខាងត្បូងជាប់និងបឹងទន្លេសាប (X 386000, X 1469500)

-ខាងកើតជាប់និងសហគមន៍នេសាទកំពង់ភ្លុក (X 382000, Y 1466500)

-ខាងលិចជាប់និងសហគមន៍នេសាទចុងឃ្នៀស (X 385000, X 1463000)

### ខ-ដែននេសាទ

កន្លែងនេសាទសហគមន៍កណ្តែក មានបឹងចំនួន០១ គ្រពាំងចំនួន០៨ អាងទឹកចំនួន ០៦និងបៀចំនួន១១ ។

| ល.រ | ឈ្មោះបឹង/អូរ/ប្រឡាយ | ទំហំ | ពេលវេលានេសាទ | ផ្សេងៗ |
|---|---|---|---|---|
| I.បឹង | | | | |
| ០១ | បឹងផ្តៅ | ទំហំ១០៨.០៩៩ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| II.ត្រពាំង | | | | |
| ០១ | ត្រពាំងដូនអ៊ី | ទំហំ២.៨១៨ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| ០២ | ត្រពាំងចង្កើ | ទំហំ១.៤៨៩ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |

| | | | | |
|---|---|---|---|---|
| ០៣ | ត្រពាំងសោម | ទំហំ០.៦២២ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| ០៤ | ត្រពាំងស្មោញ | ទំហំ១.១៩៥ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| ០៥ | ត្រពាំងខ្ទីញ | ទំហំ២.០២៧ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| ០៦ | ត្រពាំងអាអ៊ុ | ទំហំ០.៨០០ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| ០៧ | ត្រពាំងចេកខៀវ | ទំហំ០.២០០ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| ០៨ | ត្រពាំងរហាល | ទំហំ០.២៥០ ហិកតា | នេសាទពីខែមករា ដល់ខែមេសា | |
| III.អាងទឹក | | | | |
| ០១ | អាងទឹក ៧៨ | ទំហំ៦៦៦០មX ៨០០ម | នេសាទពីខែមករា ដល់ខែមីនា | |
| ០២ | អាងទឹក ទឹកថ្លា | ទំហំ១០៧ ហិកតា | នេសាទពីខែមករា ដល់ខែមីនា | |
| ០៣ | អាងទឹក កញ្ចុះ | ទំហំ១៩០០មX ១០០០ម | នេសាទពីខែមករា ដល់ខែមីនា | |
| ០៤ | អាងទឹក កូនស្នន់ | ទំហំ១៧០០មX ១២០០ម | នេសាទពីខែមករា ដល់ខែមីនា | |
| ០៥ | អាងទឹក សោម | ទំហំ១៧០០មX ១១០០ម | នេសាទពីខែមករា ដល់ខែមីនា | |
| ០៦ | អាងទឹក ក្រឡៀងដប | ទំហំ១០៩២មX ១៧០០ម | នេសាទពីខែមករា ដល់ខែមីនា | |

-ព្រៃលិចទឹកមានទំហំសរុប ៩៨១ ហិកតា

-ដីបោះបង់ចោល គ្របដណ្តប់ដោយព្រៃរបោះ មានទំហំសរុប១០០៧ ហិកតា

-វាលស្មៅ មានទំហំសរុប ទំហំ ១០ ហិកតា

-ដីកសិកម្មមានទំហំសរុប ៥៦៩ ហិកតា។

**គ-តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

ប្រជាជនចំនួនប្រមាណពី ៧០% នៅក្នុងសហគមន៍នេសាទ**កណ្តែក** ពឹងផ្អែកទៅលើទការធ្វើនេសាទ និង ធ្វើស្រែប្រាំងព្រមទាំងការប្រើប្រាស់ធនធានដែលមានក្នុងសហគមន៍ ដើម្បីចិញ្ចឹមជិវិតជាប្រចាំ។ ប្រការនេះជាជម្រើស មួយរបស់សមាជិកសហគមន៍ក្នុងការគ្រប់គ្រង អភិរក្ស និងប្រើប្រាស់ធនធានក្នុងតំបន់សហគមន៍អោយមាន និរន្តរភាព ទៅអនាគត ដើម្បីរួមចំណែកលើកស្ទួយជីវភាពប្រជាជន ក៏ដូចជាសេដ្ឋកិច្ចជាតិអោយរីកចម្រើនឡើង ។

ទិសដៅដ៏សំខាន់របស់សហគមន៍គឺបង្កើតកន្លែងអភិរក្សត្រីមេពូជ និងនាទីព្រៃលិចទឹក ដើម្បីជួយបង្កើតផលស្តុកត្រីធម្មជាតិអោយសំបូរឡើង។ កន្លែងអភិរក្សបានផ្តល់នូវវិសាលភាពដ៏ធំធេងដល់ការរស់នៅ ស្នាក់ជ្រកចំណី និងកន្លែងពងកូនរបស់មច្ឆជាតិ។ បន្ទាប់ពីការប្រមូលព័ត៌មាន និងពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍នេសាទរួច

មកគណកម្មការ បានឯកភាពគ្នាជ្រើសរើសយកទីតាំងតំបន់អភិរក្សចំនួន០១ កន្លែង សំរាប់ធ្វើតំបន់អភិរក្សត្រីមេពូជ ដូចខាងក្រោមៈ

- ត្រពាំង បឹងផ្ដៅ ទំហំ ៤ ហិតា ( បណ្ដាយ ២០០ម ទទឹង ២០០ម )

**ឃ- ធនធានជលផល**

ធនធានជលផលមានសារៈសំខាន់បំផុត ជាពិសេសត្រីបានដើរតួយ៉ាងសំខាន់សម្រាប់ការហូបចុករបស់ប្រជាពលរដ្ឋខ្មែរ និងការនាំចេញដើម្បីប្ដូរយករូបិយប័ណ្ណ មកអភិវឌ្ឍន៍ប្រទេសជាតិ ។

តាមការធ្វើអង្កេត និងការប្រមូលព័ត៌មាន ពីសំណាក់ចាស់ព្រឹទ្ធចារ្យ គណៈកម្មការ សមាជិកសហគមន៍នេ- សាទក្នុងឃុំកណ្តែកបានបង្ហាញថា ធនធានជលផលក្នុងតំបន់សហគមន៍នេសាទពេលបច្ចុប្បន្ននេះ មានការថយចុះបន្តិចបន្តួចក៏ពិតមែន ( បើប្រៀបធៀបទៅនឹងទស្សវត្សឆ្នាំ ៦០ ) តែឈរលើស្មារតីទទួលខុសត្រូវ លើការគ្រប់គ្រង និងអភិរក្សធនធានក្នុងសហគមន៍នោះ ធនធានទាំងនេះនឹងមានរីកចំរើនសំបូរឡើងជាលំដាប់។ ផ្អែកតាមការចុះ សិក្សា និងធ្វើអង្កេតលើធនធានជលផលក្នុងសហគមន៍នេសាទកណ្តែក មានដូចខាងក្រោមៈ

**តារាងប្រភេទផលនេសាទ**

| ល.រ | ប្រភេទផលនេសាទ | ល.រ | ប្រភេទផលនេសាទ |
|---|---|---|---|
| ១ | -ត្រីរៀល.ត្រីកញ្ជុះ | ១៨ | -ត្រីឆ្ពិន.ត្រីក្រុះ |
| ២ | -ត្រីព្រួល.ត្រីកញ្រ្ជូក | ១៩ | -ត្រីក្រាញ់.ត្រីលិញ |
| ៣ | -ត្រីកញ្ចាញ់ច្រាស់.ត្រីបណ្ដូលពោត | ២០ | -ត្រីកន្ត្រងប្រេង |
| ៤ | -ត្រីថ្កែក.ត្រីកំភ្នាញប្រាក់.ត្រីកំភ្លាញភ្លុក | ២១ | -ត្រី ឆ្លាំង ត្រីដៀប ត្រីឆ្ដោរ |
| ៥ | -ត្រីអង្កត់ប្រាក់ | ២២ | -ត្រីកំព្រាម |
| ៦ | -ត្រីប្រម៉ា.ត្រីរស់.ត្រីផ្ទក់ | ២៣ | -ត្រីអណ្ដាតឆ្កែ |
| ៧ | -ត្រីកញ្ជន.ត្រីស្លាត | ២៤ | -ត្រី ក្រម៉ម |
| ៨ | -ត្រីក្រាយ.ត្រីខ្ទាន់ | ២៥ | -ត្រីខ្ញឹង ត្រីកញ្រ្ជូក |
| ៩ | -ត្រីអណ្ដែង.ត្រីបន្ទស់ភ្លុក | ២៦ | -ត្រីឆ្ពួញ |
| ១០ | -ត្រីគ្រុំ | ២៧ | -ត្រីចង្វាមូល ត្រីចង្វាភ្លៀង |
| ១១ | ត្រីសណ្ដាយ.ត្រីអំពិលទុំ | ២៨ | -ត្រីក្ទាំងហាយ |
| ១២ | -ត្រីកែស | ២៩ | -ត្រីតានេល |
| ១៣ | -ត្រីតាអោន | ៣០ | -ត្រីឈ្វាត |
| ១៤ | -ត្រីដំរី | ៣១ | -ត្រីច្រកែង |
| ១៥ | -ត្រីកំភ្លៀវ | ៣២ | -ត្រីឆ្តោក និង ត្រីឆ្តោកទីទុយ |
| ១៦ | -ត្រីព្រលូង (ជួបដោយកម្រ) | ៣៣ | -ត្រីខ្នងវែង |
| ១៧ | -ត្រីស្រកាក្ដាម | ៣៤ | -ត្រីប្រាអៀវ.ត្រីប្រា.ត្រីពោ |

**តារាងប្រភេទវារីសត្វ និងបក្សីទឹក**

| ល.រ | -ប្រភេទវារីសត្វ(សិប្បីសត្វ.បាណកសត្វ.ឧរង្គសត្វ.ផលជលិត) | ល.រ | ប្រភេទបក្សីទឹក |
|---|---|---|---|

| | | | |
|---|---|---|---|
| ១ | -អណ្តើកសកល.អណ្តើកស្រែ.អណ្តើកបិទមុខ | ១ | -សត្វក្រៀល ( ជួបដោយកម្រ ) |
| ២ | -ពស់វែករនាម.ពស់ថ្លាន់.ពស់ប្រលិត | ២ | -សត្វទោម |
| ៣ | -ពស់វែកស្រង៉ែ.ពស់ទឹក.ពស់ផ្តក | ៣ | -សត្វទុង |
| ៤ | -ពស់ខ្សែគោ.ពស់តុតកែ | ៤ | -សត្វទាព្រៃ ( ជួបដោយកម្រ) |
| ៥ | -ពស់សំលាប់កង្កែប.ពស់ស្រកាចាស់ | ៥ | -សត្វប្រវីក |
| ៦ | -អន្ទង់.កង្កែប.ហ៊ីង.គីង្គក់ | ៦ | -សត្វកុក |
| ៧ | -ក្តាមទូក.កន្ទេះឡង់ | ៧ | -សត្វក្រសា (ជិតផុតពូជ) |
| ៨ | -ខ្យង.ខ្ចៅ.លៀស | ៨ | -សត្វស្មោញ |
| ៩ | -កន្ធាយ ( ជួបដោយកម្រ ) | ៩ | -សត្វក្អែកទឹក |
| ១០ | -ស្កា | ១០ | -សត្វអាអូត |
| ១១ | -ក្រពើត្រី | ១១ | -សត្វមាន់ទឹក |
| ១២ | -អន្សង ( ជិតផុតពូជ ) | ១២ | -សត្វមាន់ទោ |
| ១៣ | -ភេ ( ជួបដោយកម្រ ) | ១៣ | -សត្វកំពីងដូងំ (ជិតផុតពូជ) |
| ១៤ | -ខ្លាត្រី ( ជួបដោយកម្រ ) | ១៤ | -សត្វអញ្ជដោ |
| ១៥ | -សត្វស្វាក្រេះ | ១៥ | -សត្វត្រដក់ ( ជួបដោយកម្រ ) |
| ១៦ | -សំពោច | ១៦ | -សត្វរនៀលខ្យង ( ជួបដោយកម្រ ) |

**តារាងប្រភេទរុក្ខជាតិព្រៃលិចទឹក**

| ល.រ | ប្រភេទរុក្ខជាតិទឹក | ល.រ | ប្រភេទរុក្ខជាតិទឹក |
|---|---|---|---|
| ១ | -ដើមរាំង | ១៩ | -ដើមញព្រៃ |
| ២- | -ដើមតាអួរ | ២០ | -ដើមបន្លាយូន |
| ៣ | -ដើមអញ្ចាញ | ២១ | -ដើមស្លក |
| ៤ | -ដើមគ្រោះ | ២២ | -ដើមស្មាចទឹក |
| ៥ | -ដើមថ្វាន់ | ២៣ | -ដើមកណ្តាប់ចង្អេរ (ជិតផុតពូជ) |
| ៦ | -ដើមបបួយ | ២៤ | -ដើមរំដេញ |
| ៧ | -ដើមផ្ទោល | ២៥ | -ដើមបន្លាស្អិត |
| ៨ | -ដើមផ្តាំ | ២៦ | -ដើមច្រកែង |
| ៩ | -ដើមកន្សែង | ២៧ | -ដើមពងក្រពើ (ជិតផុតពូជ) |
| ១០ | -ដើមភ្នំភ្លៀង | ២៨ | -ដើមសំរក |
| ១១ | -ដើមកញ្ចុះ | ២៩ | -ដើមស្មៅ |
| ១២ | -ដើមខ្នាយមាន់ | ៣០ | -ដើមកំប្លោក |
| ១៣ | -ដើមបន្លាឃ្លេ | ៣១ | -ដើមត្រកូន |
| ១៤ | -ដើមឆ្អឹងពោះ | ៣២ | -ដើមព្រលិត |
| ១៥ | -ដើមជលា | ៣៣ | -ដើមញ ញៀ |

| | | | |
|---|---|---|---|
| ១៦ | -ដើមទៀនព្រៃ | ៣៤ | -ដើមធ្មេញត្រី |
| ១៧ | -វល្លិក្រអើក | ៣៥ | -ដើមភ្នែកក្រាប |
| ១៨ | -ដើមកន្តក់ | ៣៦ | -ដើមទ្រនំអាអូត |

**៤- ការធ្វើនេសាទ**

ការធ្វើនេសាទ គឺជាមុខរបរដ៏សំខាន់និងជាសកម្មភាពនៃការចិញ្ចឹមជិវិតរបស់សមាជិកសហគមន៍នេសាទ ។ នៅមុនពេលបង្កើតសហគមន៍នេសាទ ការធ្វើនេសាទតែងតែជួបប្រទះ និងទំនាស់រវាងការអ្នកនេសាទជាលក្ខណៈ គ្រួសារ និងអ្នកនេសាទជាលក្ខណៈសិប្បកម្ម ឬនេសាទឧស្សាហកម្ម ដែលជានិច្ចកាលមានទំនាស់លើដែនដី ធ្វើអាជីវ- កម្មនិងការប្រើប្រាស់ឧបករណ៍នេសាទធុនធំ គ្របដណ្តប់លើឧបករណ៍ធុនតូចៗជាដើម។ ប៉ុន្តែបន្ទាប់ពីការកែទម្រង់វិស័យ

ជលផលរបស់រាជរដ្ឋាភិបាលនាឆ្នាំ២០០០មក យើងបានផ្តល់ប្រតិភូកម្មអំណាចដល់ប្រជាពលរដ្ឋក្នុងការរៀបចំ សហគមន៍នេសាទ ហើយប្រជាពលរដ្ឋមានដែននេសាទធំទូលាយ និងកាត់បន្ថយទំនាស់ក្នុងដែននេសាទសហគមន៍ បានមួយចំណែកធំ។

យោងតាមការសិក្សា និងប្រមូលទិន្នន័យពីមូលដ្ឋាន យើងបានស្ថិតិចំនួនអ្នកនេសាទក្នុងសហគមន៍ អ្នកមិនមែនជាសមាជិក និងអ្នកមកពីខាងក្រៅសហគមន៍រួមទាំងប្រភេទឧបករណ៍នេសាទមានដូចជា ទូក កាណូត ដែល អាចធ្វើការបែងចែកជាតារាងដូចខាងក្រោម៖

**ក.អ្នកនេសាទ**

-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមាន ចំនួន ៤៩៤ គ្រួសារ

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៥២គ្រួសារ

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ២៩៥ គ្រួសារ

**ខ.ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទមានប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងមកពីក្រៅសហគមន៍ តែងតែមកធ្វើអាជីវកម្មនេសាទ ដោយប្រើឧបករណ៍ដូចជា លប មងរាយ មងអូសដៃ សន្ទូច សៃយឺន ។ល។

យោងតាមការចុះប្រមូលព័ត៌មាន ធ្វើការបំផុតគំនិត និងការប៉ាន់ស្មានលើឧបករណ៍នេសាទ ភាគច្រើនដែលបានប្រើប្រាស់ក្នុងដែននេសាទសហគមន៍បានបង្ហាញថានេសាទ មានប្រភេទឧបករណ៍នេសាទភាគច្រើនដែលបាន ប្រើស្របនឹងច្បាប់ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ដែលគណៈកម្មការ និងសមាជិកបានកំណត់រួចហើយ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏នៅមានឧបករណ៍នេសាទមួយចំនួនតូច ដែលនៅប្រព្រឹត្តល្មើស នឹងច្បាប់ មានដូចជា លបវ៉ាវ ឧបករណ៍បរ ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង ។ល។ ដែលទាមទាអោយគណៈកម្មការ និងក្រុម ល្បាត ធ្វើការអប់រំនិងទប់ស្កាត់បានទាន់ពេលវេលា។ ខាងក្រោមនេះ ជាប្រភេទឧបករណ៍នេសាទ ទូក កាណូត របស់អ្នកនេសាទដែលប្រើប្រាស់ក្នុងសហគមន៍កណ្តោក ៖

តារាងឧបករណ៍នេសាទរបស់សមាជិកសហគមន៍

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន ( គ្រួសារ ) | ទំហំ/ប្រវែង ( ជាមធ្យម/គ្រួសារ ) | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០ | ៤០០ | ពេញមួយឆ្នាំ |
| មងអូសដៃ | ម៉ែត្រ | ២៤ | ៣០-៤០ | ខែ មករា ដល់ ខែ ឧសភា |
| សន្ទូចរនង | ផ្លែ | ១០ | ៤50 | ខែ សីហា ដល់ ខែ មករា |
| បង្កៃត្រី | គ្រឿង | ៨០ | ១៥០ | ខែ សីហា ដល់ ខែ មករា |
| ទ្រូញឹក | គ្រឿង | ៥០ | ៥គូ | ខែ សីហា ដល់ ខែ មករា |
| សំណាញ់ | ម៉ែត្រ | ៣០០ | ១២ ហត្ថ | ពេញមួយឆ្នាំ |
| លបបង្កប់ | លប | ២០ | ២០-៣០ | ខែ សីហា ដល់ ខែ មករា |
| | សរុប | ៥០៤ | | |

តារាងទូក_កាណូតរបស់សមាជិកសហគមន៍

| ប្រភេទទូក-កាណូត | ចំនួន( គ្រឿង ) | ចំណុះ(គក្រ) | កំលាំងម៉ាស៊ីន ( សេះ ) |
|---|---|---|---|
| ទូកអុំ | ០ | ២០០-២៥០ | |
| កាណូតស្នាច់ | ៣០ | ២០០-៣០០ | ៦-១២ |
| **សរុប** | **៣០** | | |

តារាងឧបករណ៍នេសាទរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន ( គ្រួសារ ) | ទំហំ/ប្រវែង ( ជាមធ្យម/គ្រួសារ ) | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ០៥ | ៤០០ | ពេញមួយឆ្នាំ |
| មងអូសដៃ | ម៉ែត្រ | ០៥ | ៤០ | ខែ មករា ដល់ ខែ ឧសភា |
| សន្ទូចរនង | ផ្លែ | ០៥ | ៤៥០ | ខែ សីហា ដល់ ខែ មករា |
| បង្កៃដោត | គ្រឿង | ១០ | ១៥០ | ខែ សីហា ដល់ ខែ មករា |
| ទ្រូញឹក | គ្រឿង | ១០ | ៥គូ | ខែ សីហា ដល់ ខែ មករា |
| សំណាញ់ | ហត្ថ | ៣០ | ១២ | ពេញមួយឆ្នាំ |
| លបបង្កប់ | លប | ១០ | ៣០ | ខែ សីហា ដល់ ខែ មករា |
| | សរុប | ៧៥ | | |

តារាង-កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទទូក-កាណូត | ចំនួន ( គ្រឿង ) | ចំណុះ ( គក្រ ) | កំលាំងម៉ាស៊ីន ( សេះ ) |
|---|---|---|---|
| ទូអុំ | ០ | ៨០-១០០ | |

| | | | |
|---|---|---|---|
| កាណូតស្ទាច់ | ១៣ | ២០០-៣៥០ | ៦-១២ |
| **សរុប** | **១៣** | | |

តារាងឧបករណ៍នេសាទ របស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន ( គ្រួសារ ) | ទំហំ/ប្រវែង ( ជាមធ្យម/គ្រួសារ ) | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៥០ | ៥០០ម | ពេញមួយឆ្នាំ |
| អួនអូសដៃ | ម៉ែត្រ | ២០ | ៣០ម | ខែ មករា ដល់ ខែ ឧសភា |
| សន្ទូចរនង | ផ្លែ | ៥០ | ៤៥០ផ្លែ | ខែ សីហា ដល់ ខែ មករា |
| សំណាញ់ | ហត្ថ | ៩០ | ១០ហត្ថ | ពេញមួយឆ្នាំ |
| | សរុប | ៣១០ | | |

តារាងទូក-កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ប្រភេទទូក-កាណូត | ចំនួន( គ្រឿង ) | ចំណុះ ( គក្រ ) | កំលាំងម៉ាស៊ិន ( សេះ ) |
|---|---|---|---|
| ទូកអុំ | ០ | | |
| កាណូត | ១៣ | ២០០-៥០០ | ៦-១២ |
| **សរុប** | **១៣** | | |

គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារក្នុង១ឆ្នាំ(គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង ( គក្រ ) | រដូវវស្សា ( គក្រ ) | សរុបប្រចាំឆ្នាំ ( គក្រ ) |
| ត្រីគ្រប់ប្រភេទ | ១១០ | ២៥០ | ៣៦០ |
| ក្តាម ខ្យង | ១៥ | ២៨ | ៤៣ |
| សរុបរួម | | | ៤០៣ |

## ៥-ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

### ក.ទស្សនៈវិស័យ

ប្រជាពលរដ្ឋក្នុងសហគមន៍មានចំណេះដឹងខ្ពស់អំពីការគ្រប់គ្រងសហគមន៍នេសាទ និងមានកំរិតជីវភាព ធូរ ធារ តាមរយៈការចូលរួមអភិក្ស និងប្រើប្រាស់ធនធានធម្មជាតិក្នុងសហគមន៍ប្រកបដោយសមធម៌ និងចិរភាពដែល ជាចំណែកមួយជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

## ខ.គោលបំណង

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបឬកាត់បន្ថយពីនាទីឡូត៍នេសាទកន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវជំនោរឡើង នាទីព្រៃលិចទឹក។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌ ។

-ធ្វើអោយប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះ ដោយមានការចូលរួម។

-ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់អំពីច្បាប់ និងលក្ខន្តិករបស់សហគមន៍ ហើយចូលរួមធ្វើជាម្ចាស់លើធនធានធម្មជាតិក្នុងសហគមន៍ ។

## គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាប់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរ និងវាយ តំលៃអំពី ទំហំ ដែននេសាទ ចំនួនឧបករណ៍នេសាទ ប្រភេទឧបករណ៍នេសាទ ចំនួនអ្នកនេសាទ រដូវនេសាទ ។

ប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទដោយធ្វើយ៉ាងណាមិនអោយការធ្វើនេសាទលើសពីធនធានដែលមាននៅក្នុងដែនសហគមន៍ ។

ឆ្លងតាមការសិក្សា និងវាយតំលៃលើកត្តាដូចខាងលើ គណៈកម្មការបានរៀបចំផែនការប្រើប្រាស់ ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍មានដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ (ក្រឡា) |
|---|---|---|---|---|---|
| | | ប្រភេទឧបករណ៍ | ទំហំ/ប្រវែង | ចំនួន(គ្រួសារ) | |
| កន្លែងនេសាទសហគមន៍តាមលំហាបឹង ត្រពាំង អាងទឹក បៀ។ | ខែ០១ ដល់ខែ ១២ | -មងរាយ | ៦៥០ម | ៦៥ | (១.៥ សម) |
| | ខែ០២ ដល់ខែ ០៦ | -មងអូសដៃ | ៣០ម | ១៦ | (១.៥សម) |
| | ខែ០២ ដល់ខែ ០៥ | -លបបង្កប់ | ២០លប | ១៩ | (១.៥សម) |
| | ខែ០២ ដល់ខែ ០៥ | -លបល្អូង | ២៥លប | ១៥ | (២សម) |
| | ខែ០១ ដល់ខែ ១២ | -សំណាញ់ | ០៤ម | ១១៥ | (២.៥សម) |
| | ខែ០៧ ដល់ខែ ១២ | -លាន់ | ៤០ដើម | ០៤ | បំពង់ឬស្សី |
| | ខែ០៨ ដល់ខែ ០១ | -ទ្រូញឹក | ២០គ្រ | ៩៤ | (០.៣សម) |
| | ខែ០៨ ដល់ខែ ១១ | -បង្កៃ | ១០០ផ្លែ | ៥៤ | ផ្លែ ១ |
| | ខែ០៦ ដល់ខែ ១២ | -សន្ទូចរនង | ៨០០ផ្លែ | ៣២ | - |
| | ខែ០១ ដល់ខែ ០៥ | -លបព្រៀង | ០៥ម | ១០ | ([illegible]សម) |

### គ.២ផែនការកែលម្អដែននេសាទ

ដោយផ្អែកលើការប្រជុំពិភាក្សា រវាងអ្នកសំរបសំរួល គណៈកម្មការ និងសមាជិកសហគមន៍នេសាទ យើងពិនិត្យឃើញថា នៅក្នុងសហគមន៍នេសាទកណ្តែក មានសកម្មភាពល្មើសច្បាប់ជាច្រើនដូចជា ការកាប់ព្រៃលិចទឹក ឆក់ត្រី ការចាប់សត្វស្លាបទឹក និងលួចធ្វើនេសាទកន្លែងអភិរក្ស ។ល។ ហេតុនេះភារកិច្ចជាចំបងទាមទារការការពារ យាមល្បាត និងការចូលរួមការគាំទ្រពីសំណាក់ សមាជិក អាជ្ញាធរដែនដី និងស្ថាប័នបាក់ព័ន្ធនានាផងដែរ ។ សកម្មភាពផែនការការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមានណៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | តម្លៃប៉ាន់ស្មាន (រៀល) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងផ្តៅ | ៨ ហ.ត | ០,៥ ហ.ត | -ស្តារល្បាប់ភក់កន្លែងដែលរីងរាក់<br>-ការពារនិងអភិរក្សជម្រកត្រីមេពូជ | ២០ ០០០ ០០០ | ០៥-០៥/ ២០២០ | ០៥-០៥/ ២០២៣ |
| | | | សរុប= | ២០ ០០០ ០០០ | | |

### គ.៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ការកំណត់រៀបចំកន្លែងអភិរក្សក្នុងដែននេសាទសហគមន៍ គឺដើម្បីធានាបាននូវប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព។ ឆ្លងតាមការចុះអង្កេត ពិនិត្យ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យតាមលក្ខណៈ បច្ចេក-ទេសនោះឃើញថា តំបន់បឹងផ្តៅគឺជាតំបន់គ្រប់ដណ្តប់ដោយនាទីព្រៃលិចទឹក ដែលត្រូវបានគណៈកម្មការសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធបានមូលមតិគ្នារួម សហការបង្កើតដែនអភិរក្សត្រីមេពូជ ពពួកសត្វស្លាប។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | តម្លៃប៉ាន់ស្មាន (រៀល) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងផ្តៅ | ៨ ហ.ត | ការពារនិងអភិរក្សជម្រកត្រីមេពូជ | -បោះបង្គោលអភិរក្ស<br>-ស្លាកសញ្ញា<br>-ដាក់សម្រះនិងលូ | ៤ ០០០ ០០០<br>២ ០០០ ០០០<br>៨ ០០០ ០០០ | ០៥-០៥/ ២០២០ | ០៥-០៥/ ២០២៣ |
| | | | សរុប= | ១៤ ០០០ ០០០ | | |

### គ.៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹកមានគ្រប់ដណ្តប់លើតំបន់សហគមន៍នេសាទមួយភាគធំ ព្រៃលិចទឹកបានផ្តល់នូវសក្តានុពលភាព និងសារៈប្រយោជន៍ជាច្រើនដល់ត្រី និងពពួកវារីសត្វមានជីវិតគ្រប់ប្រភេទ សំរាប់ជាជម្រ[illegible]

ជាចំណីផងដែរ។ មិនតែប៉ុណ្ណោះនាទីព្រៃលិចទឹក បានជួយរក្សាលំនឹងបរិស្ថាន ធម្មជាតិ ទប់ស្កាត់ការហូរច្រោះ ទឹករលក ជារបាំងខ្យល់ជាដើម ជាពិសេសគឺជួយបង្កើតជលត្រី និងពពួកសត្វមានជីវិត គ្រប់ប្រភេទអោយសំបូរឡើង។

ចំពោះផែនការគ្រប់គ្រងព្រៃលិចទឹកនេះ គណៈកម្មការបានបែងចែងកំណត់ក្នុងផែនទីធនធានសហគមន៍ជាតំបន់អភិរក្ស និងតំបន់ប្រើប្រាស់រំលោះ។ តំបន់ប្រើប្រាស់គឺធ្វើយ៉ាងណាអប់រំណែនាំដល់ប្រជាជនរដ្ឋអោយចេះកាប់ រំលោះមែក (ដោយធ្វើយ៉ាងណាមិនអោយងាប់ដើម) ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។ ការកាប់រំលោះនេះគឺជាលក្ខណៈវង្វិលជុំជារៀងរាល់៣ ឆ្នាំម្តង ដើម្បីទុកអោយព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយមានការយល់ដឹងពីសារៈសំខាន់នៃព្រៃលិចទឹក ប្រជានេសាទមានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានក្នុងតំបន់អោយប្រសើរឡើង។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍ដែលគណៈកម្មការ និងសមាជិកបានរៀបចំលើកឡើងមានៈ

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើត្រូវដាំនិងការពារ | សកម្មភាព | តម្លៃប៉ាន់ស្មាន (រៀល) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ជុំវិញបឹងផ្តៅ | ១៥ហ/ត | ផ្តោល.រាំង. អញ្ចាញ ច្រកែង... | ដាំព្រៃលិចទឹក | ៧ 000 000 | ០១-០៦/ ២០២០ | ០១-០៦/ ២០២៣ |
| ការពារព្រៃសហ-គមន៍ទាំងមូល | ២៧៤៧ ហ/ត | ផ្តោល.រាំង តាអូរ ច្រកែង.... | ថែរក្សា ការពារនិងកាប់រំលោះព្រៃលិចទឹក និងយាមល្បាតជាប្រចាំថ្ងៃ ខែ ឆ្នាំ | ៨ 000 000 | ០១-១២/ ២០២០ | ០១-១២/ ២០២៣ |
| | | | សរុបៈ | ១៥ 000 000 | | |

**គ.៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ការចញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផលក្នុងការបង្កើតត្រីសាច់សំរាប់ការហូបចុករបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទ ។ គណៈកម្មការ ទាំងមូលក៏ដូចជាក្រុមផ្សព្វផ្សាយ បានអប់រំប្រជាពលរដ្ឋអោយបង្វែរមក ជាការចិញ្ចឹមត្រីដែលមិនស៊ីសាច់ជាអាហា ១០០% ដូចមានការចិញ្ចឹមត្រីតាមស្រះ ត្រីប្រា ចិញ្ចឹមត្រីកសិកម្មចំរុះ ត្រីឆ្ពិន ទីឡាព្យា ត្រីកន្ធរ ។ល។

ឆ្លើយតបទៅនិងការពង្រឹងការអភិវឌ្ឍន៍វារីវប្បកម្មនេះ គណៈកម្មការសហគមន៍នេសាទបានរៀបចំ ផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីមានដូចខាងក្រោមៈ

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន ( ស្រះ ) | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ ( ក្បាល ) | តម្លៃប៉ាន់ស្មាន (រៀល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ១០ | ឆ្តិន.ទីឡាព្យា ប្រា អណ្តែង | -ទីឡាព្យា=៤០០០ក<br>-ឆ្តិន=៤០០០ក<br>-អណ្តែង=៤០០០ក<br>-ប្រា=៤០០០ក<br>-ផ្ទក់=៤០០០ក | -៥២០ ០០០<br>-៤៨០ ០០០<br>-៨០០ ០០០<br>-៧២០ ០០០<br>-១ ២០០ ០០០ | ០៧-១២/ ២០២០ | ០៧-១២/ ២០២៣ |
| | | | សរុប= | ៣ ៧២០ ០០០ | | |

### គ.៦-ផែនការរកប្រាក់ចំណូលសហគមន៍

ចំពោះថវិកាសំរាប់ទ្រទ្រង់ និងអភិវឌ្ឍន៍សហគមន៍នេសាទ គណៈកម្មការមានតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូល និងចំណាយដោយស្របច្បាប់ តាមគ្រប់រូបភាព តាមរយៈការស្នើសុំពីអង្គការក្នុង ឬក្រៅរដ្ឋាភិបាល នានា សប្បុរសជន ចំណូលពីទុនបង្វិលប្រចាំសហគមន៍ ។

ផែនការស្វែងរកថវិកាទ្រទ្រង់សហគមន៍ ត្រូវបានរៀបចំក្នុងតារាងដូចខាងក្រោមៈ

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ចំណូល សរុប(៛) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះឈ្មោះសមាជិក | ៤០០.០០០ | ២០២០ | ២០២៣ | |
| ភាគទានប្រចាំឆ្នាំ | ផ្តល់ប័ណ្ណភាគទានប្រចាំឆ្នាំ | ១.០០០.០០០ | ២០២០ | ២០២៣ | |
| ភាគទានផ្សេងៗ | អ្នកក្រៅមកនេសាទក្នុង ស/ង | ២.០០០.០០០ | ២០២០ | ២០២៣ | |
| | សរុប= | ៣.៤០០.០០០ | | | |

### គ.៧-ផែនការអភិវឌ្ឍន៍ផ្សេងៗទៀត

| សកម្មភាព | ចំនួន | ថវិកាចំណាយ | ចាប់ផ្តើម | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ១-គ្រប់គ្រងសហគមន៍ ២០២០-២០២៣ | | | | | ថវិកាមូលនិធិឃុំ |
| -រោងយាមតំបន់អភិរក្ស | ១ | ១០ ០០០ ០០០ | ០៣/២០២០ | ០៥/២០២០ | |
| -ផ្លាកសញ្ញា | ៣ | ២ ០០០ ០០០ | ០៤/២០២០ | ១០២០២០ | |

| | | | | | |
|---|---|---|---|---|---|
| -ក្តារខៀនព័ត៌មាន | ៣ | ៣ ៨០០ ០០០ | ០៥/២០២០ | ០៨/២០២០ | |
| -បង្គោលព្រំប្រទល់ | ៥ | ៣ ៨០០ ០០០ | ០២/២០២០ | ០៥/២០២០ | |
| -ល្បាត | ៥លើក | ២ ៨០០ ០០០ | ០១/២០២០ | ១២/២០២០ | |
| -ប្រព័ន្ធទាក់ទង | ៤ | ២ ៤០០ ០០០ | ០៧/២០២០ | ០៨/២០២០ | |
| -បណ្តុះបណ្តាលគណៈកម្មការស/ន | ៦ | ២ ៤០០ ០០០ | ០៦/២០២១ | ១២/២០២១ | |
| -ផ្សព្វផ្សាយផែនការគ្រប់គ្រង | ៦ | ២ ០០០ ០០០ | ០១/២០២១ | ១២/២០២១ | |
| -ឯកសាររដ្ឋបាល/សំភារៈផ្សេងៗ | | ២ ០០០ ០០០ | ០២/២០២០ | ១២/២០២៣ | |
| -កាណូត | ១ | ១២ ០០០ ០០០ | ០១/២០២១ | ០៤/២០២១ | |
| -ស្លាកតំបន់អភិរក្ស | ១ | ២០ ០០០ ០០០ | ០៣/២០២១ | ០៥/២០២១ | |
| ២-សហគ្រាសខ្នាតតូច | | | | | ថវិកាមូលនិធិឃុំ |
| -គាំទ្របច្ចេកទេស និងបង្កើនគុណភាពផលិតផលកែច្នៃផលនេ | ៤គ្រួសារ | ២០ ០០០ ០០០ | ០២/២០២០ | ១២/២០២១ | |
| -កែច្នៃផលិតផលពីកំប្លោក | ១០គ្រួសារ | ៨ ០០០ ០០០ | ០៤/២០២០ | ០២/២០២១ | |
| -បង្កើតមុខរបរតាមឥណទាន | ២៥០នាក់ | ៩៩ ០០០ ០០០ | ០៤/២០២០ | ១២/២០២១ | |
| ៣-អភិវឌ្ឍន៍ភូមិ | | | | | ថវិកាមូលនិធិឃុំ |
| -ជីកស្រះ | ២ | ៨០ ០០០ ០០០ | ០៣/២០២០ | ០៥/២០២០ | |
| -ធ្វើរបងស្រះទឹក | ១ | ៨ ០០០ ០០០ | ០៣/២០២១ | ០៦/២០២១ | |
| -បន្ទប់ប្រជុំសហគមន៍ | ១ | ២៤ ០០០ ០០០ | ០៥/២០២០ | ១០/២០២០ | |
| -សាលារៀន | ៣បន្ទប់ | ៦០ ០០០ ០០០ | ០៤/២០២០ | ០៨/២០២០ | |
| -ចាក់គ្រួសក្រហមផ្លូវចាស់១ខ្សែ | ២០០០ ម | ៦០ ០០០ ០០០ | ០៤/២០២០ | ០៦/២០២០ | |
| -របាំងការពារទ្វាលូទឹកទំនប់ ៧៨ | ៤ | ៦០ ០០០ ០០០ | ០៤/២០២០ | ០៦/២០២០ | |
| -កែលំអផ្សារ | | ២៤ ០០០ ០០០ | ០២/២០២០ | ១០/២០២០ | |
| -អគ្គិសនីព្រះអាទិត្យ | ២ | ២៤ ០០០ ០០០ | ០៤/២០២១ | ១២/២០២១ | ២ភូមិ |
| -ចាក់គ្រួសក្រហមផ្លូវចាស់ ២ខ្សែ | ៤០០០ ម | ១២ ០០០ ០០០ | ០៣/២០២១ | ០៥/២០២១ | |
| -ទិញម៉ាស៊ីនបូមទឹកខ្នាតធំ | ១គ្រ | ២០ ០០០ ០០០ | ០១/២០២៣ | ០២/២០២៣ | ៥ភូមិ |
| -អគ្គិសនីពន្លឺព្រះអាទិត្យ | ៣គ្រ | ៤០ ០០០ ០០០ | ០៤/២០២៣ | ០៨/២០២៣ | ៣ភូមិ |
| -ឥណទានមេគោពូជ | ៩ក្បាល | ១៨ ០០០ ០០០ | ០១/២០២៣ | ១២/២០២៣ | ៣ភូមិ |
| -ធានាគារស្រូវ | ១ ក | ៤២ ០០០ ០០០ | ០១/២០២៣ | ០៥/២០២៣ | |
| -ជួសជុលផ្ទះ | ៣០០ ម | ៥០ ០០០ ០០០ | ០១/២០២៣ | ០៤/២០២៣ | |

ឃ.ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការមេនេះ

សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ព្រឹទ្ធាចារ្យ និងសមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំនេះដឹងល្អក្នុងការដឹកនាំ និងគ្រប់គ្រងការងារ ។

- សុំជំនួយបច្ចេកទេសដូចជា ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី។
- ទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថមគាំទ្រថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗ ដោយជាក់លាក់។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងទទួលបានប្រសិទ្ធភាពល្អ។
- គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- សហការដើម្បីចាត់វិធានការយ៉ាងតឹងរឹង ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ ក្នុងការអភិវឌ្ឍន៍សហគមន៍នេសាទ។
- ចងក្រងអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កណ្ដោក រយៈពេល ៣ ឆ្នាំ (២០២០ ដល់ ២០២៣)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ស្មានចំណាយ(រៀល) | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍ | -ផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុងនិងលក្ខន្តិកៈសហគមន៍<br>-ផ្សព្វផ្សាយអំពីប្រភេទឧបករណ៍ហាមឃាត់ | -ប្រជាពលរដ្ឋ៨០% មានការយល់ដឹងនិងចូលរួមអនុវត្ត | ៥.០០០.០០០ | ០១-១២/២០២០ | ០១-១២/២០២២ | ១ឆ្នាំម្ដង |
| | | សរុប | ៥.០០០.០០០ | | | |
| ២.ការកែលំអដែននេសាទ | -ស្ដារបឹងផ្ដៅ | ថែរក្សា ការពារនិងអភិរក្សជម្រកត្រីមេពូជ | ២០.០០០.០០០ | ០៤-០៥/២០២០ | ០៤-០៥/២០២២ | |
| | | សរុប | ២០.០០០.០០០ | | | |
| ៣.ការកំណត់និងរៀបចំតំបន់អភិរក្ស | -ការពារ អភិរក្សជម្រកត្រីមេពូជ | បង្គោលអភិរក្សចំនួន៨បង្គោល | ៤.០០០.០០០ | ០៤-០៥/២០២០ | ០៤-០៥/២០២២ | |
| | | ស្លាកសញ្ញាចំនួន២ស្លាក | ២.០០០.០០០ | ០៤-០៥/២០២០ | ០៤-០៥/២០២២ | |
| | | ដាក់សម្រះ គល់ និងលូ មួយចំនួនធំ | ៨.០០០.០០០ | ០៤-០៥/២០២០ | ០៤-០៥/២០២២ | |
| | | សរុប | ១៤.០០០.០០០ | | | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ដាំព្រៃលិចទឹកចំនួន១៥ហិកតា | មានព្រៃលិចទឹកល្អក្រាស់ | ៧.០០០.០០០ | ០១-០៦/២០២០ | ០១-០៦/២០២២ | |
| | -ថែរក្សា ការពារ អភិរក្ស និងការប្រើប្រាស់រំលោះ<br>-ឃាមល្បាត | -មានព្រៃលិចទឹកល្អក្រាស់ហើយប្រើប្រាស់ទៅតាមការកំណត់<br>-ឃាមល្បាតជាប្រចាំថ្ងៃ ខែ ឆ្នាំ | ៨.០០០.០០០ | ០១-១២/២០២០ | ០១-១២/២០២២ | |
| | | សរុប | ១៥.០០០.០០០ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | -ចិញ្ចឹមត្រីតាមស្រះ ១០ | -ផលត្រីកើនឡើង<br>-កាត់បន្ថយការនេសាទ | ៣.៧២០.០០០ | ០៧-១២/<br>២០២០ | ០៧-១២/<br>២០២២ | |
| | | សរុប | ៣.៧២០.០០០ | | | |
| ៦-ផែនការរកប្រាក់ចំណូលសហគមន៍ | ផ្តល់ម័ណ្ណភាគទានសមាជិកស.ន | ជីវភាពប្រជានេសាទមានការកើនឡើង តាមរយៈការបង្កើនមុខរបរបន្ថែម ( ទេសចរណ៍ធម្មជាតិ) | ៤០០.០០០ | ០១-០៨/<br>២០២០ | ០១-០៨/<br>២០២២ | |
| | ផ្តល់ម័ណ្ណភាគទានប្រចាំឆ្នាំ | | ១ ០០០.០០០ | ១២/<br>២០២០ | ១២/<br>២០២២ | |
| | ភាគទានផ្សេងៗ | | ២.០០០.០០០ | ១០-០២/<br>២០២០ | ១០-០២/<br>២០២២ | |
| | | សរុប | ២.៤០០.០០០ | | | |
| សរុបរួម | | | ៦០.១២០.០០០ | | | |

## តារាងកម្មវិធីផែនការអភិវឌ្ឍន៍ផ្សេងៗសម្រាប់សមាហរណកម្មជាមួយ ភូមិ-ឃុំ រយៈពេល០៣ឆ្នាំ(២០២០-២០២៣)

| ល.រ | ឈ្មោះកម្មវិធី ឬ គម្រោងផែនការ | អង្គភាព អនុវត្ត | លទ្ធផលរំពឹងទុក | ទីតាំងកន្លែង អនុវត្ត | រយៈពេលអនុវត្ត | | | តំលៃ ប៉ាន់ស្មាន | ប្រភព ទុន |
|---|---|---|---|---|---|---|---|---|---|
| | | | | | ២០២១ | ២០២២ | ២០២៣ | | |
| | I. គ្រប់គ្រងស.ន ២០២០-២០២៣ | | | | | | | | |
| ១ | រោងយាមតំបន់អភិរក្ស | គណៈកម្មការ ក្រុមប្រឹក្សាឃុំ | គណៈកម្មការមានទីស្នា-ក់ការបំពេញការងារ | សហគមន៍ នេសាទ | ០៣-០៥ | ០៣-០៥ | ០៣-០៥ | ១០.០០០.០០០ | ថវិកាឃុំ/ TSSLP |
| ២ | ផ្លាកសញ្ញា | គណៈកម្មការ សង្កាត់ជលផល | ប្រជាពលរដ្ឋ៨៥% មាន ការយល់ដឹងនិងចូលរួម | សហគមន៍ នេសាទ | ០៤-១០ | ០៤-១០ | ០៤-១០ | ២.០០០.០០០ | ថវិកាឃុំ/ TSSLP |
| ៣ | ក្តាខៀនព័ត៌មាន | គណៈកម្មការ ឃុំ | បំពេញតម្រូវការព័ត៌មាន រៀនសូត្រគ្រប់ចំនួន | សហគមន៍ នេសាទ | ០៣-០៨ | ០៣-០៨ | ០៣-០៨ | ៣.៨០០.០០០ | ថវិកាឃុំ/ TSSLP |
| ៤ | បង្គោលព្រំប្រទល់ | គណៈកម្មការ សង្កាត់ជលផល | ប្រជាពលរដ្ឋ៨៥% មាន ការយល់ដឹងនិងចូលរួម | សហគមន៍ នេសាទ | ០២-០៥ | ០២-០៥ | ០២-០៥ | ៣.៨០០.០០០ | ថវិកាឃុំ/ TSSLP |
| ៥ | ល្បាត | គណៈកម្មការ សហគមន៍ | ដែននេសាទសំបូរត្រី | សហគមន៍ នេសាទ | ០១-១២ | ០១-១២ | ០១-១២ | ២.៨០០.០០០ | ថវិកាឃុំ/ TSSLP |
| ៦ | ប្រព័ន្ធទាក់ទង | គណៈកម្មការ សហគមន៍ | ដែននេសាទសំបូរត្រីនិង មានសុវត្ថភាព | សហគមន៍ នេសាទ | ០៧-០៨ | ០៧-០៨ | ០៧-០៨ | ២.៤០០.០០០ | ថវិកាឃុំ/ TSSLP |
| ៧ | បណ្តុះបណ្តាលគណៈ កម្មការស.ន | គណៈកម្មការ សង្កាត់ជលផល | ប្រជាពលរដ្ឋ៩០% មាន ការយល់ដឹងនិងចូលរួម | សហគមន៍ នេសាទ | ០៦-១២ ០៣លើក | ០៦-១២ ០៥លើក | ០៦-១២ ០៥លើក | ៣.០០០.០០០ | ថវិកាឃុំ/ TSSLP |
| ៨ | ផ្សព្វផ្សាយផែនការ គ្រប់គ្រង | គណៈកម្មការ សហគមន៍ | ប្រជាពលរដ្ឋនិងឃុំ ៨៥% មានការយល់ដឹង និងចូលរួម | សហគមន៍ នេសាទ | ០១-១២ | ០១-១២ | ០១-១២ | ២.០០០.០០០ | ថវិកាឃុំ/ TSSLP |
| | ឯកសាររដ្ឋបាលនិង សម្ភារៈ ផ្សេងៗ | គណៈកម្មការ សហគមន៍ | ប្រជាពលរដ្ឋនិងឃុំ ៨៥% មានការយល់ដឹង និងចូលរួម | សហគមន៍ នេសាទ | ០២-១២ | ០២-១២ | ០២-១២ | ៣.០០០.០០០ | ថវិកាឃុំ/ TSSLP |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១០ | កាណូត | គណៈកម្មការ ឃុំ | មធ្យោបាយដឹកជញ្ជូន និងយាមល្បាត | សហគមន៍នេសាទ | ០១-០៤ | ០១-០៤ | ០១-០៤ | ១២.000.000 | ថវិកាឃុំ/ TSSLP |
| ១១ | ស្លាកតំបន់អភិរក្ស | គណៈកម្មការ ឃុំ | ជម្រកត្រីពងកូន ស៊ីចំណី និងមេពូជ | សហគមន៍នេសាទ | ០៣-០៥ | ០៣-០៥ | ០៣-០៥ | ២០.000.000 | ថវិកាឃុំ/ TSSLP |
| | II.សហគ្រាសខ្នាតតូច | | | | | | | | |
| ១២ | -គាំទ្របច្ចេកទេស និងបង្កើនគុណភាពផលិតផលកែច្នៃផលនេសាទ | | | សហគមន៍នេសាទ | ០២-១២ | ០២-១២ | ០២-១២ | ២០.000.000 | ថវិកាឃុំ/ TSSLP |
| ១៣ | -កែច្នៃផលិតផលពីកំប្លោក | | | សហគមន៍នេសាទ | ០៤-០២ | ០៤-០២ | ០៤-០២ | ៨.000.000 | ថវិកាឃុំ/ TSSLP |
| ១៤ | -បង្កើតមុខរបរតាមឥណទាន | | | សហគមន៍នេសាទ | ០៤-១២ | ០៤-១២ | ០៤-១២ | ៩៩.000.000 | ថវិកាឃុំ/ TSSLP |
| | III.អភិវឌ្ឍន៍ភូមិ | | | សហគមន៍នេសាទ | ០៤-១២ | ០៤-១២ | ០៤-១២ | ៩៩.000.000 | ថវិកាឃុំ/ TSSLP |
| ១៥ | -ជីកស្រះ | គណៈកម្មការសហគមន៍ | មានទឹកប្រើប្រាស់គ្រប់គ្រាន់ | សហគមន៍នេសាទ | ០៣-០៥ | ០៣-០៥ | ០៣-០៥ | ៨០.000.000 | ថវិកាឃុំ/ TSSLP |
| ១៦ | -ធ្វើរបងស្រះទឹក | | | សហគមន៍នេសាទ | ០៣-០៦ | ០៣-០៦ | ០៣-០៦ | ៨.000.000 | ថវិកាឃុំ/ TSSLP |
| ១៧ | -បន្ទប់ប្រជុំសហគមន៍ | គណៈកម្មការក្រុមប្រឹក្សាឃុំ | គណៈកម្មការមានទីស្នាក់ការបំពេញការងារ | សហគមន៍នេសាទ | ០៥-១០ | ០៥-១០ | ០៥-១០ | ២៤.000.000 | ថវិកាឃុំ/ TSSLP |
| ១៨ | -សាលារៀន | គណៈកម្មការ ឃុំ | បំពេញតម្រូវការសិស្សរៀនបានគ្រប់ចំនួន | សហគមន៍នេសាទ | ០៤-០៨ | ០៤-០៨ | ០៤-០៨ | ៦០.000.000 | ថវិកាឃុំ/ TSSLP |
| ១៩ | -ចាក់គ្រួសក្រហមផ្លូវចាស់១ខ្សែ | គណៈកម្មការក្រុមប្រឹក្សាឃុំ | ងាយស្រួលក្នុងការធ្វើដំណើរទៅមក | សហគមន៍នេសាទ | ០៤-០៦ | ០៤-០៦ | ០៤-០៦ | ៦០.000.000 | ថវិកាឃុំ/ TSSLP |
| | -របាំងការពារទ្វាលូទឹកទំនប់ ៧៨ | | | សហគមន៍នេសាទ | ០៤-០៦ | ០៤-០៦ | ០៤-០៦ | ៩៩.000.000 | ថវិកាឃុំ/ TSSLP |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២១ | -កែលំអផ្សារ | | | សហគមន៍ នេសាទ | ០២-១០ | ០២-១០ | ០២-១០ | ២៨.000.000 | ថវិកាឃុំ/ TSSLP |
| ២២ | -អគ្គិសនីព្រះអាទិត្យ | | | សហគមន៍ នេសាទ | ០៤-១២ | ០៤-១២ | ០៤-១២ | ២៨.000.000 | ថវិកាឃុំ/ TSSLP |
| ២៣ | -ចាក់គ្រួសក្រហមផ្លូវចាស់ ២ខ្សែ | | | សហគមន៍ នេសាទ | ០៣-០៥ | ០៣-០៥ | ០៣-០៥ | ១២.000.000 | ថវិកាឃុំ/ TSSLP |
| ២៤ | -ទិញម៉ាស៊ីនបូមទឹកខ្នាតធំ | | | សហគមន៍ នេសាទ | ០១-០២ | ០១-០២ | ០១-០២ | ២០.000.000 | ថវិកាឃុំ/ TSSLP |
| ២៥ | -អគ្គិសនីពន្លឺព្រះអាទិត្យ | | | សហគមន៍ នេសាទ | ០៤-០៨ | ០៤-០៨ | ០៤-០៨ | ៤០.000.000 | ថវិកាឃុំ/ TSSLP |
| ២៦ | -ឥណទានមេគោពូជ | | | សហគមន៍ នេសាទ | ០១-១២ | ០១-១២ | ០១-១២ | ១៨.000.000 | ថវិកាឃុំ/ TSSLP |
| ២៧ | -ធានាគារស្រូវ | | | សហគមន៍ នេសាទ | ០១-០៥ | ០១-០៥ | ០១-០៥ | ៤២.000.000 | ថវិកាឃុំ/ TSSLP |
| ២៨ | -ជួសជុលផ្ទះ | | | សហគមន៍ នេសាទ | ០១-០៤ | ០១-០៤ | ០១-០៤ | ៥០.000.000 | ថវិកាឃុំ/ TSSLP |

## តារាងកម្មវិធីការងារសហគមន៍នេសាទកណ្តោក រយៈពេល០៣ឆ្នាំ (ឆ្នាំ២០២០-២០២៣)

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១.១ ផ្សព្វផ្សាយច្បាប់ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃ | | | | | X | X | X | | | | | | | | | | X | X | X | | | | | | | | | | X | X | X | | | | | |
| ១.២ ផ្សព្វផ្សាយអំពីឧបករណ៍ហាមឃាត់ | X | X | X | X | | | | | | | | | | | | | | | | X | X | X | X | X | | | | | | | | X | X | X | X | X |
| ២.ផែនការកែលម្អដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២១ ស្តារព្រៃកំពុងភ្លុក | | | X | X | X | | | | | | | | | | X | X | X | | | | | | | | | | X | X | X | | | | | | | |
| ២២ ស្តារព្រៃរមាំងបាក់ក | | | X | X | X | | | | | | | | | | X | X | X | | | | | | | | | | X | X | X | | | | | | | |
| ៣. ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១- ការពារ អភិរក្សជម្រកត្រីព្រៃកប្រវឹក | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ៣.២-ការពារ អភិរក្សព្រៃគុប | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ៣.៣-ការពារជម្រកសត្វស្លាប | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ៣.៤ការពារ អភិរក្សព្រៃដុះថ្មី | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.១ ដាំកូនព្រៃលិចឡើងវិញ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ៤.២ អភិរក្សនិងការប្រើប្រាស់រំលោះទី១ | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.៣ អភិរក្សនិងការប្រើប្រាស់រំលោះទី២ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ៤.៤ អភិរក្សនិងការប្រើប្រាស់រំលោះទី៣ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ៤.៥ អភិរក្សនិងការប្រើប្រាស់រំលោះទី៤ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១-ចិញ្ចឹមត្រីប្រាតាមស៊ង ៤៥ | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X |
| ៥.២-ចិញ្ចឹមត្រីប្រាតាមបៃ ៥៨ | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X |
| **៦.ផែនការរកប្រាក់ចំណូលសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.១ ផ្តល់ប័ណ្ណភាគទានសមាជិកស.ន | X | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X | | | | |
| ៦.២ ផ្តល់ប័ណ្ណភាគទានប្រចាំឆ្នាំ | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X |
| ៦.៣ អភិរក្សជម្រកត្រី( NREM) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ៦.៤ អភិរក្សជម្រកត្រី (មូនិធិឃុំ) | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ៦.៥ ឥណទាន ( ចងក្រងទុនបង្វិល) | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X | | | | | X | X | X | X | X | X | X | X | | | | | X |

សូមគោរពជូន

លោកមេឃុំកណ្តែក

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ.................ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កណ្តែក, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ:.................

បានឃើញនិងគោរពជូន

លោកមេឃុំកណ្តែក

លោកនាយសង្កាត់រដ្ឋបាលជលផលប្រាសាទបាគង

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ.................ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កណ្តែក, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

**មេឃុំកណ្តែក**

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលចុងឃ្នៀស

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ.................ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ប្រាសាទបាគង, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយសង្កាត់រដ្ឋបាលជលផលប្រាសាទបាគង**

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលសៀមរាប

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ.................ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ចុងឃ្នៀស, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០

**នាយផ្នែករដ្ឋបាលជលផលចុងឃ្នៀស**

លេខ:.................

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ................. ខែ................. ឆ្នាំ.................ព.ស.២៥៦៤

សៀមរាប, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០២០

ជ. **នាយខណ្ឌរដ្ឋបាលជលផលសៀមរាប**

លេខ:.................

បានឃើញនិងគោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ថ្ងៃ................. ខែ................. ឆ្នាំ.................ព.ស.២៥៦៤

សៀមរាប, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០២០

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប**

**ធា គឹមសុទ្ធ**

លេខ:.................

បានឃើញនិងឯកភាព

ថ្ងៃ................. ខែ................. ឆ្នាំ.................ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០២០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**